# សេចក្តីសម្រេចលើនីតិវិធីបង្កើតឱ្យមានបញ្ហាកាន់តែច្រើន

**ដោយ ឡូរ៉ា ម៉ាកដូណល់**

**ថ្ងៃទី២០ ខែសភា ឆ្នាំ២០០៩**

*ប្រែសម្រួលដោយ ទែន សុខស្រីនិត*

អង្គជំនុំជម្រះសាលាដំបូងប្រឆាំង កាំង ហ្គេកអ៊ាវ (ហៅ ឌុច) បានចាប់ផ្តើមដំណើរការបន្តយូរជាងពេលធម្មតានាព្រឹកនេះដោយសារតែការប្រកាសថា សេចក្តីសម្រេចមិនទាន់បានធ្វើឡើងនៅឡើយទេ ទាក់ទិននឹងសំណូមពររបស់សហព្រះរាជអាជ្ញា អេឡិចសាន់ឌឺ ប៊េត សម្រាប់សេចក្តីណែនាំលើការអនុវត្តតាមវិធានផ្ទៃក្នុង៨៧.៣ដែលទាក់ទិននឹងផ្នែកដែលចែងថា "ភស្តុតាងពីសំណុំរឿងត្រូវតែសម្រេចចាត់ទុកថាជាភស្តុតាងនៅចំពោះមុខអង្គជំនុំជម្រះ ប្រសិនបើព័ត៌មានរបស់ភស្តុតាងនេះត្រូវបានសង្ខេប និងអានជូននៅក្នុងអង្គសវនាការ" ។ ដោយសារលោកមានបំណងដាក់ជូនអង្គជំនុំជម្រះនូវឯកសារចំនួន ១៤៨ ដែលដកស្រង់ចេញពីសក្ខីកម្មជំនាញរបស់ ក្រេក អេតឆេសាន់ លើប្រធានបទកម្ពុជាប្រជាធិបតេយ្យ អេឡិចសាន់ឌឺ ប៊េត បានស្នើសុំការអនុញ្ញាតកាលពីម្សិលមិញ ដើម្បីចុះបញ្ជីលេខឯកសារចូលទៅក្នុងតារាងបញ្ជីឯកសារ និងធ្វើសេចក្តីសង្ខេបឯកសារទាំងអស់នេះទៅតាមប្រភេទរបស់វាដើម្បីជួយសន្សំពេលវេលា ។ ដោយសារតែភាពស្មុគស្មាញនៃបញ្ហានេះ និងតម្រូវការចាំបាច់សម្រាប់ការពិភាក្សាឲ្យបានម៉ត់ចត់ ដំណើរការនីតិវិធីបានពន្យារទៅពេលរសៀល ។

បន្ទាប់ម៉ោងក្រោយមក ប្រធានចៅក្រម និល ណុន បានបដិសេធនឹងការស្នើសុំរបស់សហព្រះរាជអាជ្ញា អេឡិចសាន់ឌឺ ប៊េត ។ លោកប្រធានបានពន្យល់ថាវិធានផ្ទៃក្នុង៨៧ គឺមានសារសំខាន់ណាស់សម្រាប់ការជំនុំជម្រះក្តីដោយយុត្តិធម៌ ដូច្នេះហើយមានតែឯកសារទាំងស្រុងដែលត្រូវអាន ឬសង្ខេបប៉ុណ្ណោះនឹងត្រូវអាចសម្រេចដាក់ជូន"ចំពោះមុខអង្គជំនុំជម្រះបាន" ។ បន្ថែមលើនេះ មានតែឯកសារ ឬសៀវភៅសង្ខេបមួយចំនួនតែប៉ុណ្ណោះអាចនឹងចាត់ទុកធ្វើជាភស្តុតាងបាន ។ ដោយសារតែសេចក្តីសម្រេចនេះ ចៅក្រម ស៊ីលវ៉ា ខាតរ៉ាយថ៍ បានស្នើសុំឲ្យ ក្រេក អេតឆេសាន់ សង្ខេបគ្រប់ផ្នែកទាំងអស់ដែលមាននៅក្នុងសក្ខីកម្មដ៏ជំនាញរបស់លោក ដែលមិនទាន់បានដាក់ជូនអង្គជំនុំជម្រះ ។

បន្ទាប់មកទៀត លោកប្រធានបានផ្ទេរភារៈកិច្ចទៅឲ្យព្រះរាជអាជ្ញា អេឡិចសាន់ឌឺ ប៊ើត សួរសំណួរទៅកាន់ ក្រេក អេតឆេសាន់ ។ មុននឹងព្រះរាជអាជ្ញាឡើងនិយាយ ហ្វ្រង់ស៊័រ រូ មេធាវីការពារក្ដីបានក្រោកឈរសំណូមពរឲ្យចៅក្រមធ្វើការណែនាំដល់ព្រះរាជអាជ្ញា អាឡិចសាន់ឌឺ ប៊ើត ឲ្យសួរសំណួរទាក់ទិននឹងប្រធានបទដោយហេតុថាជនត្រូវចោទ ឌុច បានទទួលស្គាល់ហេតុការណ៍ទាំងអស់ភាគច្រើនរួចទៅហើយ ។ ហ្វ្រង់ស៊័រ រូ បានស្នើសុំឲ្យសហព្រះរាជអាជ្ញាផ្ដោតទៅលើឯកសារបី ឬបួនដែលទាក់ទិននឹងប្រធានបទដែលលើកមកពិភាក្សាបានហើយដើម្បីសន្សំពេល ។ លោកស្រីចៅក្រមបានបញ្ជាក់ថា អ្នកជំនាញអាចពន្យល់បន្ថែមលើភស្ដុតាង ដែលបានទទួលស្គាល់រួចហើយនោះបាន ។ ហ្វ្រង់ស៊័រ រូ បានឆ្លើយតបថា បើយើងពិចារណាពីកិច្ចការរបស់សាក្សីនៅក្នុងការិយាល័យរបស់សហព្រះរាជអាជ្ញានៅ អ.វ.ត.ក នោះ ក្រេក អេតឆេសាន់ គឺច្បាស់ជាគាំទ្រព្រះរាជអាជ្ញា ហើយក៏មិនមែនជាអ្នកជំនាញដែលមានការយល់ដឹងពីទំនៀមទំលាប់នោះទេ ។ ចៅក្រម ស៊ីលយ៉ា ខាតវ៉ាយថ៍ បានបន្តបញ្ជាក់ថា នេះមិនមែនជាតួនាទីរបស់ចៅក្រម ដើម្បីជម្រាបជូនភាគីណាមួយថា តើឯកសារណាត្រូវតែដាក់ជូនចំពោះមុខអង្គជំនុំជម្រះនោះទេ ហើយបានរំឭកប្រាប់ ហ្វ្រង់ស៊័រ រូ ថា លោកអាចជំទាស់នឹងឯកសារទាំងនោះដោយខ្លួនឯងបានដោយហេតុផលសមរម្យ ។

ក្រោយពីការឈប់សម្រាប់មួយរយៈពេលខ្លីមក អេឡិចសាន់ឌឺ ប៊ើត បានសួរទៅកាន់ ក្រេក អេតឆេសាន់ នូវសំណួរមួយចំនួនអំពីវិធីសាស្ត្រនិងឯកសារ ដែលដកស្រង់ចេញពីសក្ខីកម្មរបស់លោកក្នុងគោលបំណងបង្កើតជាមូលដ្ឋានមួយ សម្រាប់ដាក់ឯកសារនោះជាភស្ដុតាង នៅចំពោះមុខអង្គជំនុំជម្រះនូវឯកសារទាំង១៨៨ ដែលត្រូវបានដកស្រង់ចេញពីឯកសារចំនួន១៦០ ។ ហ្វ្រង់ស៊័រ រូ បានចាត់ទុក ក្រេក អេតឆេសាន់ ជាអ្នកនាំពាក្យរបស់ព្រះរាជអាជ្ញា ប៉ុន្ដែ អេឡិចសាន់ឌឺ ប៊ើត បានជំទាស់ថា អង្គជំនុំជម្រះត្រូវតែវាយតម្លៃលើភាពដែលអាចជឿទុកចិត្តបាននៃសេចក្ដីសន្និដ្ឋានរបស់ ក្រេក អេតឆេសាន់ ដោយធ្វើការពិនិត្យលើឯកសារយោងនៃសក្ខីកម្មរបស់លោក ។

នៅម៉ោង៣ះ៣៨នាទី អេឡិចសាន់ឌឺ ប៊ើត បានចាប់ផ្ដើមអានសេចក្ដីសង្ខេបរបស់ឯកសារទី១ នៃឯកសារទាំង១៨៨ ។ ខ្ញុំបានកត់ត្រាពេលវេលាទុក ដើម្បីឲ្យខ្ញុំអាចគិតពីរយៈពេលប៉ុន្មានម៉ោង ឬថ្ងៃដែលខ្ញុំនឹងអង្គុយស្ដាប់សេចក្ដីសង្ខេបបែបនេះ ។ នៅម៉ោង៣ះ៤៣នាទី ព្រះរាជអាជ្ញាបានចាប់ផ្ដើមអានសេចក្ដីសង្ខេបទី២នៃឯកសារទាំង១៨៨ ដែលជារបាយការណ៍មួយផ្ញើរពីប្រទេសន័រវេ ទៅឲ្យអង្គការសហប្រជាជាតិទាក់ទិននឹងការរំលោភសិទ្ធមនុស្សនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។ ជាផ្នែកមួយនៃ

សេចក្តីសង្ខេបឯកសារទី២ ការដកហូតទ្រព្យសម្បត្តិនៅតាមឃុំត្រូវបានលើកឡើង ហើយភ្លាមៗនោះ ប្រ៊ុងស៊័រ រូ បានធ្វើការជំទាស់ ។ ប្រ៊ុងស៊័រ រូ បានអះអាងថា ការដកហូតទ្រព្យសម្បត្តិមិនមានជាប់ពាក់ព័ន្ធនឹងឧក្រិដ្ឋកម្មដែលចោទប្រកាន់មកលើ ឌុច នោះទេ ។ ប្រធានចៅក្រមដែលទំនងជាយល់ស្របតាមសេចក្តីអះអាងរបស់ ប្រ៊ុងស៊័រ រូ បានអនុញ្ញាតឲ្យព្រះរាជអាជ្ញាធ្វើការឆ្លើយតប ។ នៅក្នុងដំណាក់កាលនេះ អង្គសវនាការកាន់តែមានភាពតានតឹងឡើង ។ អេឡិចសាន់ឌឺ បេ៊ត បានបញ្ជាក់ម្តងសារជាថ្មីម្តងទៀតពីមូល ហេតុពីមុនរបស់លោក ក្នុងការដាក់ឯកសារទាំងនេះនៅចំពោះមុខអង្គជំនុំជម្រះ ហើយព្រះរាជអាជ្ញាបានបន្ថែមទៀតថា សម្រាប់ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ព្រះរាជអាជ្ញាត្រូវតែចាត់ទុកថា ឧក្រិដ្ឋកម្មដែលបានកើតមានឡើងនោះមានលក្ខណៈជាប្រព័ន្ធឬរាលដាលទូទាំងប្រទេស ហើយម្យ៉ាងទៀត ឧក្រិដ្ឋកម្មរបស់ ឌុច គឺជាផ្នែកមួយនៃឧក្រិដ្ឋកម្ម ដែលមានលក្ខណៈជាប្រព័ន្ធនិងរាលដាលបែបនេះ ។ ដោយកត់សម្គាល់មានការជំទាស់ឥតឈប់ឈរពីសំណាក់មេធាវីការពារក្តី ព្រះរាជអាជ្ញាបានយល់ឃើញថាមេធាវីការពារក្តីមានបំណងដាក់កម្រិតលើចំនួនឯកសារ ហើយបានក្រើនរំឭកដល់ចៅក្រមពីតួនាទីរបស់ខ្លួនក្នុងការអប់រំសាធារណជន និងបង្ហាញឲ្យឃើញថា តុលាការអន្តរជាតិមួយនេះប្រព្រឹត្តទៅដោយការជំនុំជម្រះក្តីត្រឹមត្រូវយុត្តិធម៌ដោយយោងទៅតាមភស្តុតាង ។ ព្រះរាជអាជ្ញា បានជម្រុញធ្វើយ៉ាងណាឲ្យភស្តុតាងរបស់តុលាការផ្សព្វផ្សាយជាសាធារណៈ ។ ដោយពិចារណាពីរបាយការណ៍ជាច្រើនដែលរៀបរាប់ពីអំពើពុករលួយ និងការខ្វះខាតនូវភាពត្រឹមត្រូវច្បាស់លាស់នៅឯអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា អេឡិចសាន់ឌឺ បេ៊ត បានសួរទៅកាន់ចៅក្រមថា «តើយើងចង់សម្រេចបានអ្វីពីដំណើរការនីតិវិធីនេះ» ?

មុននឹងអនុញ្ញាតឲ្យភាគីដទៃទៀតមានឱកាសនិយាយ ចៅក្រមបានធ្វើការពិភាក្សាដ៏ក្តៅគគុកមួយដោយមានការបង្ហាញកាយវិការប្រចបូកប្រចបល់គ្នាយ៉ាងច្រើន ជាពិសេសគឺចៅក្រម ឡាវែន់ ។ មេធាវីដើមបណ្តឹងរដ្ឋប្បវេណីបានគាំទ្រព្រះរាជអាជ្ញាយ៉ាងខ្លាំង ។ មេធាវីដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់បានរំឭកថាអង្គជំនុំជម្រះបានកោះហៅ ក្រេក អេតឆេសាន់ ដែលជាអ្នកជំនាញដ៏សំខាន់ម្នាក់មកពិភាក្សាពីបញ្ហាដែលស្ថិតនៅខាងក្រៅវិសាលភាពបទឧក្រិដ្ឋនៅមន្ទីរស-២១ ។ ដូច្នេះ សម្រាប់ជាប្រយោជន៍ដល់យុត្តិធម៌ និងការស្វែងរកការពិតនោះ ភស្តុតាងដែលមានលក្ខណៈពេញលេញគឺពិតជាមានសារសំខាន់ ។ ប្រ៊ុងស៊័រ រូ បាននិយាយជាលើកចុងក្រោយ ។ លោកបានយល់ស្របថា របាយការណ៍របស់ ក្រេក អេតឆេសាន់ ពិតជាមានសារសំខាន់ ហើយបានស្នើសុំថា អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាគួរតែដាក់របាយការណ៍នេះនៅលើគេហទំព័ររបស់អង្គជំនុំជម្រះ ដើម្បីអប់រំសាធារណជន ។ ផ្ទុយពី

ប្រព័ន្ធច្បាប់ខមែនឡូរ៍ ហ្វ្រង់ស័រ រូ បានអះអាងថានៅក្នុងប្រព័ន្ធច្បាប់ស៊ីវិលឡូរ៍ ចៅក្រមមិនចាំបាច់ពិនិត្យមើលគ្រប់ឯកសារ ដើម្បីចេញសេចក្តីសម្រេចផ្តន្ទាទោសនោះទេ ។ លោកបានបន្តទៀតថា ចៅក្រមគឺត្រូវសម្រេចការផ្តន្ទាទោស ដោយផ្អែកលើហេតុការណ៍ដែលមាននៅក្នុងបទចោទប្រកាន់ ។ សារជាថ្មីម្តងទៀត ចៅក្រមទាំងអស់បានធ្វើការពិភាក្សាគ្នា ប៉ុន្តែមិនអាចធ្វើសេចក្តីសម្រេចលើបញ្ហានេះនៅឡើយទេ ។ ប្រធានចៅក្រមមានប្រសាសន៍ថា ការពិភាក្សាដេញដោលគាន់តែមានភាពតានតឹងដូច្នេះការពិភាក្សានេះត្រូវផ្អាកទៅធ្វើនៅថ្ងៃក្រោយ ។

ទាំងព្រះរាជអាជ្ញា និងមេធាវីការពារក្តីបានថ្លែងពីសេចក្តីអំណះអំណាងរបស់ខ្លួនបានយ៉ាងល្អនៅក្នុងថ្ងៃនេះ ។ នៅក្នុងដំណើរការនីតិវិធីនេះ ភាគីទាំងពីរបាននិយាយប្រឆាំងគ្នាទៅវិញទៅមក ។ ខ្ញុំមិនដឹងថាតើចៅក្រមនឹងធ្វើសេចក្តីសម្រេចលើបញ្ហានេះដោយរបៀបណានោះទេ ប៉ុន្តែខ្ញុំប្រាកដនៅក្នុងចិត្តថា អេឡិចសាន់ឌឺ បើត និង ហ្វ្រង់ស័រ រូ នឹងមិនបរិភោគអាហារពេលល្ងាចជាមួយគ្នាទេនៅពេលល្ងាចនេះ ។